# គោលបំណង ផលប៉ះពាល់ លទ្ធផល

## គោលដៅ

គម្រោងមានគោលដៅពង្រឹងគុណភាពនៃការអប់រំនៅតាមសាលារៀន ដោយផ្តោតការគាំទ្រដ៏ប្រយ័ត្នប្រយែងចំពោះការអភិវឌ្ឍនិងការគ្រប់គ្រងប្រព័ន្ធអប់រំ (២) ការអភិវឌ្ឍវិជ្ជាជីវៈ គ្រូបង្រៀន (៣) ការពង្រឹងការអប់រំនៅមធ្យមសិក្សា។

## ឥទ្ធិពល

ឥទ្ធិពលនៃគម្រោង នឹងគឺជាកំណើនចំនួនប្រជាជនដែលបានទទួលការអប់រំនិងមានជំនាញកាន់តែប្រសើរឡើងនៅក្នុងគ្រប់មជ្ឈដ្ឋានទាំងអស់នៃប្រជាជនកម្ពុជា ជាពិសេស សិស្សនារីនិងសិស្សមកពីតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក។

## លទ្ធផល

លទ្ធផលរបស់គម្រោង នឹងគឺជាការលើកស្ទួយគុណភាពនិងសមធម៌នៃការអប់រំនៅកម្ពុជា ជាមួយការអប់រំនៅមធ្យមសិក្សាកាន់តែមានប្រសិទ្ធភាព សមត្ថភាពគ្រូបង្រៀនកាន់តែប្រសើរឡើង និងប្រព័ន្ធគ្រប់គ្រងអប់រំកាន់តែរឹងមាំឡើង។

## ថវិកាគម្រោង

| | | គិតជាដុល្លារអាមេរិក |
|---|---|---|
| ក. | សំណង់ | ៣.៤១៩.៨០០ |
| ខ. | សម្ភារនិងគ្រឿងសង្ហារឹម | ៣.៩៥៣.០០០ |
| គ. | ធនធានមណ្ឌលសិក្សា | ៣.៤០០.០០០ |
| ឃ. | សៀវភៅនិងសម្ភារបង្រៀន | ១.៣៤៦.០០០ |
| ង. | រថយន្ត | ៣៤៨.០០០ |
| ច. | បណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាពបច្ចេកទេស | ៨.១១៩.៤០០ |
| ឆ. | កម្មវិធីផ្តល់អាហារូបករណ៍ | ១.២២០.០០០ |
| ជ. | សេវាពិគ្រោះការ | ៥.៨៣៦.០០០ |
| ឈ. | ចំណាយចរន្ត | ៣.២៨៨.៥០០ |
| ញ. | បម្រុង | ២.៤៥៧.២០០ |
| **ថវិកាគម្រោងសរុប** | | **៣៣.៣៨៧.៨០០** |
| | ធនាគារអភិវឌ្ឍន៍អាស៊ី | ២៧.១០០.០០០ |
| | រាជរដ្ឋាភិបាលកម្ពុជា | ៦.២៨៧.៨០០ |

# រចនាសម្ព័ន្ធគ្រប់គ្រងគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង EEQP គឺថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៨។

គម្រោងនេះត្រូវបានដឹកនាំដោយគណៈកម្មាធិការដឹកនាំគម្រោង (PSC) មួយ និង គ្រប់គ្រងដោយក្រុមមន្ត្រីគ្រប់គ្រងគម្រោង (PMS) មួយ ដែលរួមមាននាយកគម្រោងមួយរូប ប្រធានគម្រោងមួយរូប និង មន្ត្រីជំនួយមួយចំនួន។




ក្រសួងអប់រំ យុវជន និង កីឡា

# គម្រោងលើកកម្ពស់គុណភាពអប់រំ (EEQP)

## ជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី លេខ 0090-CAM(SF)




**អគ្គនាយកដ្ឋានអប់រំ**

លេខ ១៦៩ មហាវិថីព្រះនរោត្តម

រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខ: (+៨៥៥) ២៣ ២១១ ២១៧

ទូរសារលេខ: (+៨៥៥) ២៣ ២២០ ៤៥៣

អ៊ីម៉ែល: eeqp@wicam.com.kh

គេហទំព័រ: www.moeys.gov.kh/eeqp



Managed by coffey international development SPECIALISTS IN DEVELOPING COMMUNITIES

In association with CSCS

## សមាសភាគទី ១:
## ការគ្រប់គ្រងនិងការអភិវឌ្ឍប្រព័ន្ធអប់រំ

### លទ្ធផលរំពឹងទុក

១. ការយល់ដឹងអំពីច្បាប់ស្តីពីការអប់រំ និង គោលនយោបាយ បញ្ញោបយេនឌ័ររបស់ក្រសួងអប់រំ យុវជន និង កីឡា
២. ក្របខ័ណ្ឌគោលនយោបាយសម្រាប់ការងារគ្រប់គ្រងនិងការអប់រំគ្រូបង្រៀន
៣. ការពិនិត្យឡើងវិញលើតួនាទីនិងមុខងារនៃក្រសួងអប់រំ យុវជន និង កីឡា នៅរដ្ឋបាលថ្នាក់កណ្តាល រាជធានី-ខេត្ត ស្រុក-ខ័ណ្ឌ និង សាលារៀន
៤. ការពង្រឹងវិទ្យាស្ថានជាតិអប់រំ
៥. ពង្រឹងប្រព័ន្ធពតិមាននៅថ្នាក់ជាតិ រាជធានី-ខេត្ត ស្រុក-ខ័ណ្ឌ និង សាលារៀន
៦. ដាក់ឱ្យដំណើរការប្រព័ន្ធពិនិត្យតាមដាននិងប្រព័ន្ធធានាគុណភាពនៅតាមសាលារៀននិងសាលាគរុកោសល្យ
៧. ការកែលម្អសមត្ថភាពនៃនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា និង ក្រុមប្រឹក្សាអនុម័តសម្ភារអប់រំ។



## សមាសភាគទី ២:
## ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន

### លទ្ធផលរំពឹងទុក

១. ការលើកកម្ពស់សមត្ថភាពគ្រប់គ្រងនៃស្ថាប័នបណ្តុះបណ្តាលគ្រូ
២. ការធ្វើឱ្យប្រសើរឡើងនូវសម្ភាររូបវ័ន្ត រួមទាំង ICT នៅតាមស្ថាប័នបណ្តុះបណ្តាលគ្រូ
៣. ការបង្កើនការចូលរៀនរបស់គរុសិស្សនារីនិងគរុសិស្សមកពីតំបន់ជួបការលំបាកនៅសាលាគរុកោសល្យរាជធានី-ខេត្ត និង វិទ្យាស្ថានជាតិអប់រំ
៤. ការបង្កើនសមត្ថភាពនិងបំណិនគ្រូឧទ្ទេសនៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ
៥. ការបង្កើនសមត្ថភាពនិងបំណិនគ្រូបង្រៀននៅមធ្យមសិក្សា
៦. ណែនាំឱ្យចេះពីរបៀបប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយចម្រុះសម្រាប់ការងារបណ្តុះបណ្តាលគ្រូ។



## សមាសភាគទី ៣:
## ការពង្រឹងការអប់រំនៅមធ្យមសិក្សា

### លទ្ធផលរំពឹងទុក

១. ផែនការអភិវឌ្ឍន៍អប់រំមធ្យមសិក្សា
២. ការពង្រឹងបណ្តាញសាលារៀនមធ្យមសិក្សា ការគ្រប់គ្រងសាលារៀន និង ការធ្វើផែនការកែលម្អសាលារៀន
៣. ការបង្កើនការចូលរៀនរបស់សិស្សនារី និង កុមារមកពីតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក
៤. ការធ្វើឱ្យប្រសើរឡើងនូវសម្ភាររូបវ័ន្តសាលាមធ្យមសិក្សា
៥. កម្មវិធីសិក្សាតាមផ្នែកជាអាទិភាព រួមទាំង ICT ត្រូវបានអភិវឌ្ឍ និង ប្រើប្រាស់ក្នុងសាលាមធ្យមសិក្សា
៦. ការផ្គត់ផ្គង់សៀវភៅសិក្សាគោល និង សៀវភៅគ្រូដល់សាលាមធ្យមសិក្សាទុតិយភូមិទាំងអស់
៧. ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាគឺផ្អែកលើស្តង់ដារកម្មវិធីសិក្សា។

